THE SCHOOL DISTRICT OF PHILADELPHIA

ការិយាល័យ អគ្គនាយក
440 North Broad Street
Philadelphia, PA 1913

**William R. Hite, Jr., Ed.D.**
អគ្គនាយក

ថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២០

ជូនចំពោះ ក្រុមគ្រួសារ របស់ក្រសួងអប់រំ ជាទីគោរព៖

**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាបានប្រកាសបន្តបិទសាលាដោយគ្មានកំណត់ រហូតដល់មានការជូនដំណឹងបន្ថែម។**
ការការពារ សុខភាព និង សុខុមាលភាពរបស់ សិស្សានុសិស្ស បុគ្គលិក និង សហគមន៍នៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា គឺជាអាទិភាពសំខាន់បំផុតរបស់យើង។ យើងនឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនីញ៉ា ក្រសួងសុខភាពសាធារណៈនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា និង ទីភ្នាក់ងារដទៃទៀត ដើម្បីសម្រេចថាតើនៅពេលណាដែលយើងអាចបើកសាលាបានឡើងវិញដោយសុវត្ថិភាព។ លិខិតនេះផ្តល់នូវព័ត៌មានសំខាន់ៗស្តីពីដំណើរការរបស់ក្រសួងជុំវិញ វិស្សមកាលនៅនិទាឃរដូវ និង កម្មវិធីថ្មី ដើម្បីជួយដល់ការរៀនសូត្រនៅតាមផ្ទះរបស់សិស្សានុសិស្សទាំងអស់។

<u>វិស្សមកាលនៅនិទាឃរដូវ</u>
ក្រសួងនឹងឱ្យសាលាមានវិស្សមកាលនៅនិទាឃរដូវ ចាប់ពីថ្ងៃទី ៦ ដល់ថ្ងៃទី ៩ ខែមេសា ហើយក្រសួងនឹងបិទនៅថ្ងៃសុក្រ ទី ១០ ខែមេសា សម្រាប់ថ្ងៃរំឭកដល់ការស្លាប់របស់ព្រះយេស៊ូគ្រីស្ត ដូចដែលយើងបានគ្រោងទុក។ ខ្ញុំដឹងថា នេះមើលទៅ ឬ មានអារម្មណ៍ថាមិនដូចជាវិស្សមកាលនៅនិទាឃរដូវដូចធម្មតានោះទេ ប៉ុន្តែយើងចង់ឱ្យអ្នកអប់រំរបស់យើងមានពេលវេលាជាមួយគ្រួសារ និងនៅឆ្ងាយពីការងារ ដូចជាពេលដែលពួកគាត់មាននៅក្នុងឆ្នាំសិក្សាធម្មតា។

<u>កុំព្យូទ័រក្រូមប៊ុក (Chromebook) សម្រាប់សិស្ស* ថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ១២</u>
គឺជាផ្នែកមួយនៃផែនការសិក្សាតាមកុំព្យូទ័រ ក្រសួងនឹងឱ្យសិស្ស ថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ១២ របស់ក្រសួងណាដែលត្រូវការខ្ចីកុំព្យូទ័រក្រូមប៊ុក សម្រាប់ការរៀននៅផ្ទះ។ យើងក៏នឹងបង្កើតឱ្យមានឯកសារសិក្សាតាមកុំព្យូទ័រ ដើម្បីជួយសិស្សឱ្យបន្តការសិក្សា និង ប្រើចំណេះដឹង និង វិធីសាស្ត្រ ដោយមានជំនួយពីគ្រូ។ កម្មវិធីឱ្យខ្ចីនេះគឺឥតគិតថ្លៃ ហើយមិនតម្រូវថាត្រូវតែចូលរួមនោះទេ។ បើសិនជាកូនរបស់លោកអ្នកត្រូវការ កុំព្យូទ័រក្រូមប៊ុក ដើម្បីរៀននៅផ្ទះ លោកអ្នកមិនបាច់ធ្វើអ្វីទេនៅពេលនេះ។ នាយកសាលានឹងជូនដំណឹងដល់ក្រុមគ្រួសារអំពីពេលវេលាជាក់លាក់ ដែលពួកគាត់អាចទៅយក កុំព្យូទ័រក្រូមប៊ុក ពីសាលារបស់កូនៗពួកគាត់។ ក៏មានឱកាសផ្សេងទៀតដែរ សម្រាប់ក្រុមគ្រួសារដែលមិនបានដឹងពីពេលវេលាចែកចាយរបស់សាលា។

កុំព្យូទ័រទាំងអស់ត្រូវប្រគល់ឱ្យសាលាវិញ នៅពេលសាលាបើកដំណើរការឡើងវិញ។ លោកអ្នកអាចស្វែងយល់បន្ថែមអំពីកម្មវិធីនេះដោយចូលមើលវិបសៃ www.philasd.org/coronavirus/chromebooks។ បើសិនជាលោកអ្នកមានលទ្ធភាពនិងមានកុំព្យូទ័រនៅផ្ទះដើម្បីជួយដល់ការរៀនសូត្ររបស់កូនលោកអ្នក យើងស្នើសុំឱ្យលោកអ្នកទុកកម្មវិធីនេះសម្រាប់ឱ្យអ្នកដែលគ្មានលទ្ធភាព។

ម្ហូបអាហារ និង ការណែនាំអំពីការសិក្សា

ការណែនាំអំពីការសិក្សា សម្រាប់ថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ១២ និង ម្ហូបអាហារដែលលោកអ្នកអាចទៅយក មានសម្រាប់សិស្សានុសិស្សនៅកន្លែងទាំង ៤៩ របស់ក្រសួង នៅថ្ងៃច័ន្ទ និង ថ្ងៃព្រហស្បតិ៍ ចាប់ពីម៉ោង ៩ ព្រឹក ដល់ថ្ងៃត្រង់។

នៅមានសំណួរជាច្រើនដែលត្រូវការចម្លើយ។ យើងសុំឱ្យលោកអ្នកមានការអត់ធ្មត់ នៅពេលដែលយើងកំពុងបន្តរៀបចំ និងជានិច្ចជាកាលតែងតែយកចិត្តទុកដាក់បំផុតពីសិស្សានុសិស្សរបស់យើង។ ដើម្បីជ្រាបព័ត៌មានបន្ថែម លោកអ្នកអាចទាក់ទងមកយើងខ្ញុំតាមរយៈការហៅទូរស័ព្ទទៅបណ្តាញខ្សែទូរស័ព្ទសំខាន់របស់ក្រសួង ផ្ញើអ៊ីមែលមកយើងខ្ញុំតាម covid19info@philasd.org ចូលមើលវិបសៃ www.philasd.org និងចូលរួមជាមួយខ្ញុំនៅ @PhillySchools Facebook Live រៀងរាល់ថ្ងៃពុធ វេលាម៉ោង ៣ រសៀល។

សូមថែរក្សាខ្លួនឱ្យបានល្អ និង រក្សាសុវត្ថិភាព!



William R. Hite Jr., Ed.D.
អគ្គនាយក
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

*សម្គាល់៖ ក្រុមគ្រួសារសិស្សថ្នាក់មុនមត្តេយ្យ (Pre-K) នឹងមិនទទួលកុំព្យូទ័រទេ ដោយអនុលោមតាមការណែនាំរបស់វេជ្ជបណ្ឌិតកុមារអាមេរិកាំង ដើម្បីកំណត់ពេលមើលកុំព្យូទ័រសម្រាប់កុមារអាយុពី ២ ទៅ ៥ ឆ្នាំ។ ក្រុមគ្រួសាររបស់សិស្សថ្នាក់មុនមត្តេយ្យនឹងទទួលបានច្បាប់ចម្លងនៃការណែនាំអំពីការសិក្សា តាមប៉ុស្តិ៍សំបុត្រក្នុងរយៈពេលពីរសប្តាហ៍ខាងមុខ ដើម្បីជួយដល់ការអភិវឌ្ឍន៍របស់កូនលោកអ្នក។ គ្រូថ្នាក់មុនមត្តេយ្យ នឹងទាក់ទងទៅគ្រួសារនីមួយៗ ក្នុងខណៈពេលដែលសាលារៀនត្រូវបិទ ដើម្បីជួយដល់ការរៀនសូត្រនៅតាមផ្ទះ និងឆ្លើយសំណួរដែលក្រុមគ្រួសារអាចមាន។